# របាយការណ៍សកម្មភាពការងារប្រចាំខែ កញ្ញា ឆ្នាំ ២០១៧ របស់នាយកដ្ឋានសវនកម្មផ្ទៃក្នុង

I. **ស្ថានភាពទូទៅ**

II. នាយកដ្ឋានសវនកម្មផ្ទៃក្នុង មានមន្ត្រីសរុបចំនួន ១៧ រូប (ស្រី ០៥ រូប) ក្នុងនោះមន្ត្រីកម្មសិក្សា ចំនួន ០២ រូប (ស្រី ០១ រូប) ៖

- ចំនួនមន្ត្រីរាជការ ដែលស្ថិតក្នុងភាពទំនេរគ្មានបៀវត្ស ៖ គ្មាន
- ចំនួនមន្ត្រីរាជការ ដែលបានទៅបំពេញបេសកកម្មនៅក្រៅប្រទេស ៖ គ្មាន
- មន្ត្រីរាជការ សម្រាកលំហែមាតុភាព ៖ គ្មាន
- ចំនួនឈឺ ៖ គ្មាន
- ចំនួនមន្ត្រីរាជការ ដែលបានសហប្រតិបត្តិការជាមួយអង្គការ និងកម្មវិធី ៖ គ្មាន
- ចំនួនមន្ត្រីរាជការ ស្ថិតនៅក្នុងស្ថានភាពទំនេរពីការងារ ៖ ០១រូប

III. **លទ្ធផលការងារ**

1. **ការងារសវនកម្ម**

- ចុះធ្វើសវនកម្មលើការគ្រប់គ្រងរដ្ឋបាល ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ថវិកាតាមកម្មវិធី ឆ្នាំ ២០១៦ -២០១៧ និងចុះពិនិត្យជាក់ស្តែងការងារសាងសង់ ជួសជុលអណ្តូងទឹក និងសាងសង់បង្គន់អនាម័យដោយប្រើប្រាស់ថវិការដ្ឋ **នៅមន្ទីរអភិវឌ្ឍន៍ជនបទខេត្តចំនួន ០៤** រួមមាន ខេត្តស្ទឹងត្រែង រតនគីរីរាជធានីភ្នំពេញ និងខេត្តកំពង់ឆ្នាំង ។

2. **ការងារប្រជុំ និងបណ្តុះបណ្តាល**

ថ្នាក់ដឹកនាំ និងមន្ត្រី បានចូលរួមកិច្ចប្រជុំចំនួន ០១ លើកសិក្ខាសាលាចំនួន ០២ លើក និង បណ្តុះបណ្តាលចំនួន ០១ លើក៖

- **ការងារប្រជុំ**

- គ្មានសកម្មភាព។

- **សិក្ខាសាលា**

- ប្រធាននាយកដ្ឋាន ចូលរួមសិក្ខាសាលាស្តីពី " ការផ្សព្វផ្សាយបច្ចេកទេសថ្មីៗ នៃការសាងសង់ ជួសជុល និងថែទាំផ្លូវជនបទ និងការគ្រប់គ្រងហេដ្ឋារចនាសម្ព័ន្ធផ្លូវជនបទ នៅថ្ងៃទី ៣០ ខែសីហា ឆ្នាំ ២០១៧ សណ្ឋាគារភ្នំពេញ រាជធានីភ្នំពេញ
- ប្រធាននាយកដ្ឋាន ចូលរួមជាគណៈអធិបតីក្នុងពិធីបើក និងបិទសិក្ខាសាលាស្តីពី ដាក់ឲ្យដំណើរការគម្រោង ( Lunching Workshop ) គ្រប់គ្រងគ្រោះមហន្តរាយនៅកម្ពុជា និងអាស៊ីអាគ្នេយ៍នៅថ្ងៃទី ០៥-០៦ ខែកញ្ញា ឆ្នាំ ២០១៧ សណ្ឋាគារ Raffles Hotel le Royal ភ្នំពេញ។

- **បណ្តុះបណ្តាល**

- អនុប្រធានការិយាល័យ និងមន្ត្រីសរុបចំនួន ០៣រូប(ស្រី ០១រូប)ចូលរួមក្នុងកម្មវិធី "ផ្សព្វផ្សាយស្តីពីអាហារូបករណ៍ក្រោមកម្មវិធី JDS របស់មជ្ឈមណ្ឌលសហប្រតិបត្តិការអន្តរជាតិជប៉ុន (JICE) " នៅថ្ងៃទី ០៤ ខែកញ្ញា ឆ្នាំ ២០១៧ សាលប្រជុំជាន់ទី ០៣ នៃក្រសួងអភិវឌ្ឍន៍ជនបទ។

3. **កម្មវិធីផ្សេងៗ**

- គ្មានសកម្មភាព។